អេស៊ីលីដា ត្រេននីង សេនធ័រ
ACLEDA Training Center Ltd.

**ការិយាល័យកណ្ដាល**
លេខ : អត្រស ២៣០៨ /១៤

**អគ្គនាយក អេស៊ីលីដា ត្រេននីង សេនធ័រ**

**គោរពជូន**

**តំណាងសមាជិកសមាជិកា ក្រុមគ្រូហ្វឹកហ្វឺននៃនាយកដ្ឋាន ទីផ្សារ អភិវឌ្ឍន៍ផលិតផល ការិយាល័យនីតិកម្ម ការិយាល័យលេខាធិការក្រុមហ៊ុន ការិយាល័យធនធានមនុស្ស ការិយាល័យពិធីការ ការិយាល័យរដ្ឋបាល និងក្រុមហ៊ុន អេស៊ីលីដា ស៊ីយូ្យរីធី ភីអិលស៊ី**

**កម្មវត្ថុ :** **ស្តីពីវគ្គហ្វឹកហ្វឺន កម្មករនិយោជិត ថ្មីសម្រាប់ មុខតំណែង « អ្នកសំអាត អ្នកបើកបររថយន្ត និងជំនួយការបម្រើអតិថិជន »**

**យោង :**
- សេចក្តីសម្រេចលេខ : អត្រស ០៩៧/១៤ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវគោលការណ៍ប្រតិបត្តិ ហ្វឹកហ្វឺន និងអភិវឌ្ឍន៍ធនធានមនុស្ស ។
- អនុស្សរណៈនៃការយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការ និងគាំទ្រ លើសេវាហ្វឹកហ្វឺនផ្ទៃក្នុងកម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី រវាង ធនាគារ អេស៊ីលីដា ភីអិលស៊ី និង អេស៊ីលីដា ត្រេននីង សេនធ័រ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៣ និងការធ្វើវិសោធនកម្ម ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៣ ។
- សេចក្តីសម្រេចលេខ : អត្រស ២៨៤៧/១៣ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវកម្មវិធីហ្វឹកហ្វឺនកម្មករនិយោជិតថ្មី របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ។
- លិខិតលេខ : កធម ២៨៩៦/១៤ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤ ស្តីពីតម្រូវការរៀបចំបើកវគ្គហ្វឹកហ្វឺនកម្មករនិយោជិតថ្មី ។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងយោងខាងលើ អេស៊ីលីដា ត្រេននីង សេនធ័រ នឹងរៀបចំបើកវគ្គ ហ្វឹកហ្វឺនកម្មករនិយោជិតថ្មី ដែលនឹងប្រព្រឹត្តទៅចាប់ពី**ថ្ងៃទី២៧ ខែតុលា** ដល់**ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤** នៅ**អេស៊ីលីដា ត្រេននីង សេនធ័រ** ( **ជាន់ទី៤ បន្ទប់ប្រាសាទបន្ទាយស្រី** ) ដែលមានទីតាំងស្ថិតនៅ **អគារលេខ៥០ ផ្លូវលេខ៥១៦ កែង៣៣៥ ភូមិ៦ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ**។

អេស៊ីលីដា ត្រេននីង សេនធ័រ សូមអញ្ជើញសមាជិក-សមាជិកាក្រុមគ្រូហ្វឹកហ្វឺន នៃនាយកដ្ឋាន ទីផ្សារ អភិវឌ្ឍន៍-ផលិតផល ការិយាល័យនីតិកម្ម ការិយាល័យលេខាធិការក្រុមហ៊ុន ការិយាល័យធនធានមនុស្ស ការិយាល័យ ពិធីការ ការិយាល័យរដ្ឋបាល និងក្រុមហ៊ុន អេស៊ីលីដា ស៊ីយូ្យរីធី ភីអិលស៊ី ដើម្បីចូលរួម ដឹកនាំមេរៀនតាមកម្មវិធី ដូចបានជូនភ្ជាប់មកជាមួយ ។

អាស្រ័យហេតុនេះ សូមតំណាងសមាជិក-សមាជិកាក្រុមគ្រូហ្វឹកហ្វឺន់ននាយកដ្ឋាន ការិយាល័យ និងក្រុមហ៊ុនខាងលើមេត្តាចាត់ចែង ឲ្យក្រុមគ្រូហ្វឹកហ្វឺន រៀបចំឯកសារមេរៀនផ្នែកហ្វឹកហ្វឺនខាងក្នុង ដើម្បីរៀបចំថតចម្លង ឯកសារឲ្យបានទាន់ពេល ។

ដោយក្តីគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ភ្នំពេញ, ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤

**ជ, អគ្គនាយក**

**នាយិកាការិយាល័យសិក្សា និងកិច្ចការនិស្សិត**

**ថ្ងូនភ្ជាប់មកជាមួយ** :

- កាលវិភាគហ្វឹកហ្វឺន

This is an electronic letter sent by Sovanne Tourt

**ចម្លងជូន** :

- ទីប្រឹក្សាអេស៊ីលីដា គ្រេននីង សេនជ័រ
- នាយិកាប្រតិបត្តិទីផ្សារ
- នាយកប្រតិបត្តិអភិវឌ្ឍន៍ផលិតផល
- នាយិកាការិយាល័យទំនាក់ទំនងអតិថិជន

« **ដើម្បីជូនជ្រាបជាព័ត៌មាន** »

- ឯកសារ - កាលប្បវត្តិ